ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការរកឃើញ ០៦ ករណីថ្មីទៀត ជាបុរសជនជាតិខ្មែរឥស្លាមដែលវិលត្រឡប់មកពីចូលរួមពិធីសាសនា នៅប្រទេសម៉ាឡេស៊ី និង ០៣ ករណីថ្មី ជាបុរសជនជាតិម៉ាឡេស៊ី វិជ្ជមានវីរុសកូវីដ១៩

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានបង្ហាញ **វិជ្ជមានវីរុសកូវីដ១៩ ចំនួន០៩នាក់** ជាករណីថ្មីបន្ថែមទៀត ដែលមានដូចខាងក្រោមនេះ៖

**១. នៅខេត្តសៀមរាប៖ ០១ ករណី**

- បុរសជនជាតិខ្មែរឥស្លាម១នាក់ អាយុ ៤០ឆ្នាំ វិជ្ជមានកូវីដ១៩ នៅភូមិតាកុង ឃុំសំបួរ ស្រុកសៀមរាប ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តសៀមរាប។

**២. នៅរាជធានីភ្នំពេញ៖ ០២ ករណី**

- បុរសខ្មែរឥស្លាមចំនួន ០២នាក់ (អាយុ ២៧ឆ្នាំ និងអាយុ ៤០ឆ្នាំ) នៅសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

**៣. នៅខេត្តកំពង់ឆ្នាំង៖ ០១ ករណី**

- បុរសខ្មែរឥស្លាមចំនួន ០១នាក់ (អាយុ ៣៦ឆ្នាំ) នៅភូមិត្រពាំងថ្មី ឃុំឈូកស ស្រុកកំពង់ត្រឡាច មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង។

**៤. នៅខេត្តកែប៖ ០៣ ករណី**

- ជនជាតិម៉ាឡេស៊ី ចំនួន ០៣នាក់ (អាយុ ៥៨ឆ្នាំ ៦១ឆ្នាំ និង ៦៦ឆ្នាំ) មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ក្នុងចំណោមជនជាតិម៉ាឡេស៊ី ០៥នាក់ ដែលមកពីប្រទេសម៉ាឡេស៊ី (២នាក់ អវិជ្ជមានវីរុសកូវីដ១៩) ហើយពួកគាត់ទាំង៣នាក់នេះ ត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តកែប រីឯ ២ នាក់ទៀត ដាក់ឲ្យនៅដាច់ដោយឡែកនៅក្នុងព្រះវិហារឥស្លាមក្នុងខេត្តកែប ដើម្បីតាមដានសុខភាពក្នុងរយៈពេល១៤ថ្ងៃ។

**៥. នៅខេត្តកោះកុង៖ ០១ ករណី**

- បុរសខ្មែរឥស្លាមចំនួន ០១នាក់ (អាយុ ៥៧ឆ្នាំ) នៅភូមិត្រើយកោះ ឃុំត្រើយកោះ ស្រុកដងទង់ ខេត្តកំពត មាន

តេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តកោះកុង ដោយសារអ្នកជំងឺបច្ចុប្បន្ននេះនៅធ្វើការនៅខេត្តកោះកុង។

**៦. នៅខេត្តត្បូងឃ្មុំ៖ ០១ ករណី**

- បុរសខ្មែរឥស្លាមចំនួន ០១នាក់ (អាយុ ៥៣ឆ្នាំ) នៅភូមិទ្រា២ ឃុំទ្រា ស្រុកក្រូចឆ្មារ មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តត្បូងឃ្មុំ(នៅពញាក្រែក)។

*សម្គាល់៖ បុរសជនជាតិឥស្លាមទាំង០៩នាក់ខាងលើនេះ ជាអ្នកក្នុងចំណោមអ្នកដែលបានវិលត្រឡប់មកពីការចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ីសរុបចំនួន៧៩នាក់។ សរុបជនជាតិឥស្លាមដែលវិលត្រឡប់មកពីការចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ីដែលវិជ្ជមានវីរុសកូវីដ១៩ គឺ ១៩នាក់ ក្នុងចំណោម ៧៩នាក់ និងមានបុរសជនជាតិម៉ាឡេស៊ី ០៣នាក់ វិជ្ជមានវីរុសកូវីដ១៩ ដែលមកពីប្រទេសម៉ាឡេស៊ី។*

ក្រុមឆ្លើយតបបន្ទាន់និងក្រុមគ្រូពេទ្យថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ កំពុងបន្តតាមដានរកអ្នកប៉ះពាល់យ៉ាងសកម្ម ជាពិសេសអ្នកដែលបានចូលរួមនៅក្នុងពិធីសាសនាឥស្លាម នៅប្រទេសម៉ាឡេស៊ីកន្លងមកនេះបន្ថែមទៀត។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេស ប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ៩រោច ខែផល្គុន ឆ្នាំជូត ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩